## ប្រទេសកម្ពុជា



| | |
|---|---|
| ចំនួនប្រជាជន | 14.3 លាននាក់ |
| កំណើនប្រជាជន | 1.2 ភាគរយ |
| ផសស (គិតជាពាន់លានដុល្លារអាមេរិកលើមូលដ្ឋាន PPP) | 33.9 |
| ផសស ក្នុងពលរដ្ឋម្នាក់ (លើមូលដ្ឋាន PPP) | 2,372 |
| ផសស ក្នុងពលរដ្ឋម្នាក់ (លើមូលដ្ឋានPPP) | 2,372 |
| ផ្ទៃដី | 181,040 គ.ម២ |
| រាជធានី | ភ្នំពេញ |

ប្រភព: *World Development Indicators*

## កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចកាលពីពេលថ្មីៗកន្លងទៅ

កាលពីឆ្នាំមុន (២០១១) ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ កំណើននេះឡើងដល់ ៧,១ ភាគរយ ក្នុងរយៈពេល ៤ ឆ្នាំដោយសារការងើបឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យកសិកម្ម និងការបង្កើនការនាំចេញ ការវិនិយោគរបស់ឯកជន និងសាធារណៈ ព្រមទាំងការប្រើប្រាស់ដែលមានការកើនឡើង។

កំណើននៅឆ្នាំ ២០១២ ត្រូវបានព្យាករណ៍ថាគន្លងអភិវឌ្ឍន៍នឹងកើនឡើង ប៉ុន្តែមានល្បឿនយឺតជាងពីមុន ក្នុងអត្រាប្រមាណជា ៦,៦ ភាគរយ (ដូចការព្យាករណ៍របស់ធនាគារពិភពលោកនាខែ មេសា ឆ្នាំ ២០១២)។ ទោះជាយ៉ាងណាក្តី តទៅអនាគតកំណើនត្រូវបានមើលឃើញថានៅតែមានស្ថានភាពល្អ ដែលអត្រាកំណើនមធ្យមរយៈពេលមធ្យមមានកម្រិតប្រហែល ៧,០ ភាគរយក្នុងមួយឆ្នាំសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។

ការនាំចេញទំនិញភាគច្រើនទៅ ទីផ្សារសហរដ្ឋអាមេរិក និងទីផ្សារសហភាពអឺរ៉ុប ត្រូវបានរំពឹងថានឹងមានល្បឿនយឺតជាងកាលពីពេលមុន ធ្វើឱ្យកំណើននៅឆ្នាំ ២០១២ មានកម្រិតទាបជាង។ ការនាំចេញទំនិញរបស់កម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងកើនឡើង ១១ ភាគរយ នៅឆ្នាំនេះ (ធៀបនឹង ៣៤ ភាគរយនៅឆ្នាំ ២០១១)។ ការនាំចេញទំនិញត្រូវបានប៉ាន់ស្មានថា មានល្បឿនយឺតជាងពីពេលមុន ដោយសារការធ្លាក់ចុះកំណើននាំចេញទៅទីផ្សារសហរដ្ឋអាមេរិក និងទីផ្សារសហភាពអឺរ៉ុបក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ ហើយនៅតែបន្តមានកំណើនយឺតនៅឆមាសទីពីរផងដែរ។ ការនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋ អាមេរិក តាមពិតកើនឡើង ២,០ ភាគរយ ប៉ុណ្ណោះ ក្នុងឆមាសទីមួយនៃឆ្នាំ ២០១២ (ធៀបនឹង ១៨ ភាគរយ ក្នុង រយៈពេលដូចគ្នា កាលពីឆ្នាំមុន) ខណៈដែលការនាំចេញ សម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបបានកើនឡើងត្រឹមតែ ២៩ ភាគរយប៉ុណ្ណោះ (ធៀបនឹង ៦១ ភាគរយ ក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំមុន)។ ផលប៉ះពាល់ដោយផ្ទាល់ មកលើវិស័យឧស្សាហកម្ម ត្រូវបានកាត់បន្ថយដោយសារ វិស័យសំណង់មានលទ្ធផលល្អប្រសើរនៅឆមាសទីមួយ នៃឆ្នាំ ២០១២ មានអត្រាកំណើនកើនឡើងបីដង (គិតជាដុល្លារ) នូវគំរោងថ្មីដែលបានអនុម័តនៅភ្នំពេញ និងកំណើន ៣៦ ភាគរយនៃគំរោងដែលបានឯកភាពនៅ ទូទាំងប្រទេស។ ហេតុនេះ កំណើន វិស័យឧស្សាហកម្ម (គិតទាំងសំណង់) ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះដល់ ៩,៧ ភាគរយសម្រាប់ឆ្នាំ ២០១២ (ធៀបនឹង ១៤,៥ ភាគរយ កាលពីឆ្នាំមុន)។ ជាមួយ

គ្នានេះ វិស័យសេវាកម្មមានកំណើនខ្ពស់ជាងការរំពឹងទុក កាត់បន្ថយសម្ពាធសេដ្ឋកិច្ច ហើយត្រូវបានព្យាករណ៍ថា នឹងកើនឡើង ៦,៨ ភាគរយនៅឆ្នាំនេះ (ធៀបនឹង ៥,០ ភាគរយនៅឆ្នាំ ២០១១)។ ចំណុចខ្លាំងនៃវិស័យសេវាកម្ម ត្រូវបានអូសទាញដោយសន្ទុះរីកចម្រើនខ្លាំងនៃ វិស័យទេសចរណ៍ និងវិស័យហិរញ្ញវត្ថុ។ ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ បានហក់ឡើងខ្ពស់ដល់ ២៧ ភាគរយនៅឆមាសទីមួយនៃឆ្នាំ ២០១២ (ធៀបនឹង ១៤ ភាគរយក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន)។ គេរំពឹងថាប្រទេសកម្ពុជានឹងទទួលភ្ញៀវទេសចរ ៣,៤ លាននាក់នៅឆ្នាំនេះ ពោលគឺកើនឡើងចំនួន ១៨ ភាគរយ។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុមានសភាពរស់រវើកជាខ្លាំង ខណៈដែលប្រាក់បញ្ញើ ត្រូវបានប៉ាន់ស្មានថានឹងកើនឡើង ២៤ ភាគរយដល់ ៦,៤ ពាន់លានដុល្លារ[1] ហើយការផ្តល់ឥណទានត្រូវបានព្យាករណ៍ថា នឹងកើនឡើង ៣៤ ភាគរយរហូតដល់ ៥,៧ ពាន់លានដុល្លារនៅចុងឆ្នាំ ២០១២។

ទោះបីជាបានជួបការរាំងស្ងួត និងជំនន់ដែលមានលក្ខណៈរដូវកាលខ្លះៗក៏ដោយ វិស័យកសិកម្មត្រូវបានរំពឹងថានៅតែមានខ្ពស់ក្នុងកម្រិត ៣,០ ភាគរយនៅឆ្នាំ ២០១២។ បរិមាណទឹកប្រាក់ គិតជាដុល្លារនៃអង្ករនាំចេញបានកើនឡើង ១៥ ភាគរយធៀបនឹងឆមាសទីមួយនៃឆ្នាំ ២០១១ ទោះជាមាន បរិមាណតិចជាងចំពោះបរិមាណនាំចេញអង្ករនៅឆមាសទីមួយនៃឆ្នាំ ២០១២ក្តី (៧៦ ពាន់តោននៅឆមាសទីមួយនៃឆ្នាំ ២០១២ ធៀបនឹង ៨៥ ពាន់តោនក្នុងកំឡុងពេលដូចគ្នានៅឆ្នាំ ២០១១) ។ ការមានលទ្ធភាពជ្រៀតចូលទីផ្សារថ្មីៗ ដោយសារចិន (កម្ពុជាបាននាំចេញជិត ១.៣០០ តោន ក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ ២០១២) និងអាហ្វ្រិកផ្តល់ឱកាសដល់ការពង្រីកទីផ្សារអង្កររបស់ប្រទេសកម្ពុជា។ កន្លងមក ប្រទេសបារាំងនៅតែជាទីផ្សារគោលដៅសំខាន់បំផុតតែមួយគត់ ដែលស្រូបអង្ករនាំចេញ ស្រូបយកជិតមួយភាគបីនៃអង្ករនាំចេញសរុបនៅឆមាសទីមួយនៃឆ្នាំ ២០១២។

ផ្នែកសំខាន់មួយនៃកំណើនរបស់កម្ពុជា គឺការប្រើប្រាស់របស់ផ្នែកឯកជនដែលបន្តកើនឡើង ស្មើនឹង ៨៧ ភាគរយនៃផលិតផលសង្គមសរុប (ផសស)នៅឆ្នាំ ២០១១ (កើនឡើងពី ៨៤ ភាគរយនៃ ផសស នៅឆ្នាំ ២០១០)។ ចំណាយឯកជនពិតក្នុងម្នាក់ៗបានកើនឡើង ៩ ភាគរយក្នុងរយៈពេលពីរឆ្នាំ ហើយកើនឡើងជិតទ្វេដង ប្រសិនបើប្រៀបធៀបជាមួយទសវត្សកន្លងទៅ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវសកម្មភាពឯកជនយ៉ាងច្រើន។

វិស័យក្រៅប្រទេស ត្រូវបានរំពឹងថា នឹងធ្លាក់ចុះបន្តិចនៅឆ្នាំ ២០១២ ដោយការការធ្លាក់ចុះនូវការនាំចេញ។ ឱនភាពនៃសមតុល្យគណនីចរន្ត ត្រូវបានព្យាករណ៍ថានឹងកើនឡើង ១០ ភាគរយនៃ ផសស (ពី ៨,៧ ភាគរយនៃ ផសស កាលពីឆ្នាំមុន)។ ឆ្នាំ ២០១២ លំហូរវិនិយោគផ្ទាល់ពីបរទេស ត្រូវបានរំពឹងថានឹងមានទំហំប្រមាណជា ៩,៣ ភាគរយនៃផសស ។ គំរោងថ្មីចំនួនចិតសិបពីរត្រូវបានផ្តល់ការយល់ព្រមនៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១២ ដឹកនាំដោយវិនិយោគិនចិន និងកូរ៉េ (ធៀបនឹងគំរោងចំនួន ៥៧ ដែលបានឯកភាពកាលពីឆ្នាំមុន)។ ក្នុងពេលជាមួយគ្នានេះ ចំនួនក្រុមហ៊ុនថ្មីដែលបានចុះបញ្ជី និងបានទទួលការឯកភាពនៅក្រសួងពាណិជ្ជកម្មក៏បានកើនឡើងដល់ ១.៧១២ នៅឆមាសទីមួយនៃឆ្នាំ ២០១២ (ធៀបនឹង ១.៥៦៣ ក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំមុន)។ ប្រាក់បំរុងបរទេសដុលបន្តកើនឡើង រហូតដល់ ៣.២ ពាន់លានដុល្លារកាលពីខែមិថុនាឆ្នាំ ២០១២ ហើយត្រូវបានព្យាករណ៍ថានឹងមានចំនួន ៣.៥ ពាន់លានដុល្លារនៅចុងឆ្នាំ ២០១២ ដែលអាចធ្វើការនាំចូលបានចំនួន ៤,៥ ខែ។

ផលប៉ះពាល់នៃការកើនឡើងនូវថ្លៃស្បៀងអាហារអន្តរជាតិកាលពីពេលថ្មីៗ មកលើអតិរណាថ្លៃទំនិញប្រើប្រាស់របស់កម្ពុជាស្ទើរតែគ្មាន។ ថ្លៃស្បៀងអាហារពិភពលោកបានកើន

[1] ប្រាក់ដុល្លារទាំងអស់គឺជាដុល្លារអាមេរិក វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ

ឡើងកាលពីប៉ុន្មានខែកន្លងទៅឡើងដល់កម្រិតវិបត្តិស្បៀងអាហារឆ្នាំ ២០០៨ នៅខែកក្កដាឆ្នាំ២០១២ សំអាងលើសន្ទស្សន៍ថ្លៃស្បៀងអាហាររបស់ធនាគារពិភពលោក ដែលវាស់ថ្លៃអន្តរជាតិនៃកន្ត្រកទំនិញ ដូចជាធញ្ញជាតិ បន្លែ ប្រេង និងសាច់ ជាដើម ។ ទោះជាយ៉ាងណាក៏ដោយ ការឡើងនូវថ្លៃចំបងៗកន្លងមកកើតមានចំពោះ ស្រូវសាលី ពោត និងសណ្តែកសៀង ដែលមិនតំណាងភាគរយខ្ពស់នៃកន្ត្រកប្រើប្រាស់ស្បៀងអាហារនៅកម្ពុជាឡើយ។ ថ្លៃទំនិញប្រើប្រាស់នៅ កម្ពុជាត្រូវបានរក្សាស្ថេរភាពក្នុងឆមាសទីមួយនៃឆ្នាំនេះ ខណៈដែលថ្លៃអង្ករ (អាហារសំខាន់)កើនឡើងបន្តិចបន្តួចប៉ុណ្ណោះ (ជាមធ្យម កើនឡើង ៣ ភាគរយក្នុងកំឡុងពេលនេះ ខណៈដែលថ្លៃស្រូវជាមធ្យមនៅទីផ្សារអន្តរជាតិបានកើនឡើង ១២ ភាគរយ)។ អតិផរណាថ្លៃទំនិញប្រើប្រាស់ ដែលបានធ្លាក់ចុះក្នុងឆមាសទីមួយនៃឆ្នាំ ២០១២ ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះប្រមាណ ជា ៤ ភាគរយនៅចុងឆ្នាំ ២០១២ (ពី ៤,៩ ភាគរយ កាលពីឆ្នាំមុន) មកលើមុខទំនិញស្បៀងអាហារដែលមានស្ថេរភាពមានទំហំជិតពាក់កណ្តាល នៃកន្ត្រកអតិផរណាថ្លៃទំនិញប្រើប្រាស់ និងមកលើថ្លៃថាមពល។

ក្នុងពេលជាមួយគ្នានោះ អត្រាផ្តូរប្រាក់ជាក់ស្តែងមានស្ថេរភាព ខណៈដែលថ្លៃប្រាក់រៀលបានកើនឡើង ១,៣ ភាគរយធៀបនឹងប្រាក់ដុល្លារសហរដ្ឋ អាមេរិកក្នុងខែមិថុនា ឆ្នាំ ២០១២ (អត្រាចុងគ្រា)។ ដូចគ្នាដែរ អត្រាប្តូរប្រាក់ប្រសិទ្ធរបស់កម្ពុជាក៏បានកើនឡើង ៣ ភាគរយ ធៀបនឹងកន្ត្រកក្រុមប្រទេសនាំចេញសម្លៀកបំពាក់ប្រាំបួន ផ្សេងទៀត ដែលធ្វើឱ្យមានហានិភ័យអំពីការធ្លាក់ចុះនូវភាពប្រកួតប្រជែងក្នុងការនាំចេញរបស់កម្ពុជា។ គោលនយោបាយ អន្តរាគមន៍របស់ធនាគារជាតិកម្ពុជាបានអនុវត្តជាបន្ត: ធនាគារជាតិបានបញ្ចេញប្រាក់រៀលដែលមានតម្លៃស្មើនឹង ១១៧ លានដុល្លារទៅក្នុងទីផ្សារ ក្នុងឆមាសទីមួយនៃឆ្នាំ ២០១២។ ការលក់ឬទិញរូបិយបណ្ណបរទេស ត្រូវបានជឿថាមានប្រសិទ្ធភាព ក្នុងការរក្សាស្ថេរភាពប្រាក់រៀលនៅកម្ពុជា ខណៈដែលប្រាក់រៀលមានបរិមាណតិចតួចនៅក្នុងសេដ្ឋកិច្ច។

វិស័យហិរញ្ញវត្ថុបានបន្តកើនឡើងក្នុងបរិស្ថានដុល្លារូបនីយកម្មខ្ពស់។ វិបត្តិប្រាក់អឺរ៉ូទំនងជាមានផលប៉ះពាល់តិចតួចមកលើប្រព័ន្ធធនាគារ ឬមកលើការ វិនិយោគលើផលប័ត្រ ដោយសារ សមាហរណកម្មហិរញ្ញវត្ថុរបស់កម្ពុជាទៅក្នុងពិភពលោកមានកម្រិតទាប។ ការិយាល័យឥណទានកម្ពុជាដែលទើបដំណើរការ (ត្រូវបានប្រកាសដាក់ឱ្យដំណើរការកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) នឹងដើរតួកាន់តែសំខាន់ក្នុងការជួយការពារ និងកាត់បន្ថយហានិភ័យឥណទាន និងគាំទ្រកំណើននៃប្រព័ន្ធធនាគារ។ ត្រឹមខែមិថុនា ឆ្នាំ ២០១២ មានធនាគារពាណិជ្ជចំនួន ៣៩ កំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា (ក្នុងរយៈពេល ១២ ខែចុងក្រោយ មានធនាគារថ្មីចំនួនបួន បានចូលមកក្នុង ទីផ្សារកម្ពុជា)ជាមួយនឹងការបន្តផ្តល់ឥណទាន ដែលមានកំណើនយ៉ាងខ្ពស់។ កំណើនផ្តល់ឥណទាននៃធនាគារជាមធ្យមបានកើនឡើង ៣៤ ភាគរយក្នុងមួយខែ ក្នុងរយៈពេលប្រាំមួយខែចុងក្រោយ (ការផ្តល់ឥណទានជិតពាក់កណ្តាល ផ្តោតលើពាណិជ្ជកម្មលក់ដុំ/លក់រាយ សកម្មភាពពាក់ព័ន្ធវិស័យទេសចរណ៍ និង កម្មន្តសាល) ដែលសឱ្យឃើញនូវកំណើនយ៉ាងខ្ពស់នៃវិស័យឯកជន ប៉ុន្តែក៏សឱ្យឃើញថាអាចមាន ហានិភ័យហិរញ្ញវត្ថុ និងបញ្ហាប្រឈមអំពីសមត្ថភាពត្រួតពិនិត្យផងដែរ។ ធនាគារជាតិនៃកម្ពុជា (ធនាគារកណ្តាល) បានបង្កើនអត្រាប្រាក់បំរុងកាតព្វកិច្ចពី ១២ ភាគរយទៅ ១២.៥ ភាគរយ ជាដំណើរឆ្ពោះទៅរកការរឹតបន្តឹង គោលនយោបាយរូបិយវត្ថុ និងដើម្បីដោះស្រាយបញ្ហាសន្ទុះខ្លាំងក្លានៃឥណទានកាលពីប៉ុន្មានខែកន្លងទៅ។ ក្នុងខែ កក្កដា ឆ្នាំ ២០០៨ ធនាគារកណ្តាលបានបង្កើនអត្រាប្រាក់បំរុងកាតព្វកិច្ចពី ៨ ភាគរយដល់ ១៦ ភាគរយ ដើម្បីបង្ការផលប៉ះពាល់នៃ វិបត្តិហិរញ្ញវត្ថុពិភពលោក។ ក្រោយមកនៅខែ មករា ឆ្នាំ២០០៩ ធនាគារកណ្តាលបាន

ទម្លាក់ អត្រានេះពី ១៦ ភាគរយមកត្រឹម ១២ ភាគរយ ប៉ុណ្ណោះ ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ច។

លើផ្នែកសារពើពន្ធវិញ រដ្ឋាភិបាលបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីពង្រឹងការគ្រប់គ្រងចំណូល និងលើកកំពស់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធធនាគារកាលពីពេលថ្មីៗ ដោយរដ្ឋាភិបាលក្នុងការប្រមូលពន្ធ ការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវការប្រមូលពន្ធអចលនទ្រព្យ និងការពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ដើម្បីគ្របដណ្តប់ការិយាល័យគយបន្ថែមទៀតនឹងជួយបង្កើនការប្រមូលចំណូលសម្រាប់រយៈពេលមធ្យម។ កាលពីថ្ងៃ ទី ៣ ខែ មករា ឆ្នាំ ២០១២ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដើម្បីជម្រុញការគ្រប់គ្រងថវិកាប្រកបដោយជំនឿទុកចិត្ត។ យុទ្ធសាស្ត្រកៀរគចំណូលត្រូវបានព្រាង ហើយរំពឹងថានឹងដាក់ជូនរដ្ឋាភិបាលសម្រេចនៅឆ្នាំក្រោយ។ ទោះជាយ៉ាងណាក្តី ការប្រមូលចំណូលនៅឆ្នាំ ២០១១មិនបានកើនឡើងច្រើនឡើយ (១៣,២ ភាគរយនៃ ផសស នៅឆ្នាំ ២០១១ ស្មើនឹងឆ្នាំ ២០១០)ហើយចំណាយទូទៅរបស់រដ្ឋាភិបាលមិនប្រែប្រួល ស្មើនឹង ២០,៦ ភាគរយនៃ ផសស នៅឆ្នាំ ២០១១ ឱនភាពសារពើពន្ធនៅតែមានកម្រិតស្មើនឹងឆ្នាំ ២០១០ ស្មើនឹង ៧,៤ ភាគរយនៃ ផសស នៅឆ្នាំ ២០១១ (ធៀបនឹង ៧,៥ ភាគរយនៃ ផសស នៅឆ្នាំ ២០១០ នៅពេលដែលរដ្ឋាភិបាលធ្វើការកាត់ចំណាយចរន្តមិនចាំបាច់យ៉ាងច្រើន) ។ ឱនភាពសារពើពន្ធ នៅតែមានកម្រិតខ្ពស់ជាងកម្រិតឱនភាពជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ប៉ុន្តែសរុបមកគេរំពឹងថា នឹងប្រសើរជាងមុនក្នុងរយៈពេលមធ្យម ដោយសារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រឹង ព្រមទាំងមានយុទ្ធសាស្ត្រកៀរគប្រាក់ចំណូល។ រដ្ឋាភិបាលនៅមិនទាន់មានលទ្ធភាពសន្សំស្មើនឹងកម្រិតមុនពេលមានវិបត្តិនៅឡើយ ដែលត្រូវបង្កើតឱ្យមានប្រាក់បំរុងចាំបាច់សម្រាប់ទប់ទល់វិបត្តិ ដែលអាចកើតឡើងជាយថាហេតុ។ ក្នុងខែមិថុនា ឆ្នាំ ២០១២ប្រាក់បំរុង រដ្ឋាភិបាលមានកម្រិត ៤,២ ភាគរយនៃ ផសស (ធៀបនឹង ៦,៤ ភាគរយនៃ ផសស នៅខែមិថុនា ឆ្នាំ ២០០៨)។

ចំណាយចរន្ត និងចំណាយមូលធនយ៉ាងច្រើន (ភាគច្រើនចំណាយលើ គំរោងវិនិយោគអភិវឌ្ឍន៍របស់រដ្ឋាភិបាល) បន្តជាមុខចំណាយសារពើពន្ធ ចំបងនៅឆ្នាំ ២០១១។ ចំណាយមូលធន នៃគំរោងវិនិយោគសាធារណៈនៅឆ្នាំ ២០១១ ត្រូវបានប៉ាន់ស្មានថាស្មើនឹង ៨,៧ ភាគរយនៃ ផសស ខ្ពស់ជាងមធ្យមភាគរយៈពេលប្រាំឆ្នាំកន្លងទៅដែលមានអត្រា ៧,២ ភាគរយ មួយផ្នែកធំជាប់ពាក់ព័ន្ធជាមួយកម្ចីសម្បទាន គិតទាំងចំណាយឥណទានរបស់ចិនផងដែរ។ និន្នាការនៃចំណាយវិនិយោគមូលធនច្រើន ត្រូវបានរំពឹងថានឹងបន្តកើនឡើងសម្រាប់ ឆ្នាំ ២០១២ និង ២០១៣។ ជាមួយគ្នានោះ ចំណាយហិរញ្ញប្បទានក្នុងស្រុកចំពោះវិស័យសង្គម ពោលគឺ វិស័យសុខាភិបាល និងវិស័យអប់រំនៅបន្តទទួល អាទិភាពខ្ពស់ ហើយការបើកផ្តល់ថវិកាកាន់តែប្រព្រឹត្តទៅបានទាន់ពេលវេលា។

លទ្ធភាពសម្រាប់តុល្យភាពសារពើពន្ធឆ្នាំនេះ និងឆ្នាំក្រោយត្រូវបានរំពឹងថា មានលក្ខណៈល្អប្រសើរ ដោយហេតុថាការប្រមូលចំណូលបានកើនឡើង។ ការប្រមូលចំណូលបានកើន ២៩ ភាគរយនៅឆមាសទីមួយនៃឆ្នាំ ២០១២ ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំកន្លងទៅ ដែលកំណើននេះ មានទំនាក់ទំនងជាមួយកំណើនពន្ធផ្ទាល់ និងពន្ធប្រយោល (៣៥ ភាគរយ និង ២៨ ភាគរយ ក្នុងកំឡុងឆមាស ទីមួយនៃឆ្នាំ ២០១១)។ ខណៈដែលការគ្រប់គ្រងសារពើពន្ធស្ថិតក្នុងសភាពអាចគ្រប់គ្រងបាន ការផ្តល់ហិរញ្ញប្បទានពីបរទេស ដែលមិនអាចប៉ាន់ស្មានជាមុនបាន កាន់តែងាយរងផលប៉ះពាល់ ហើយបង្កើនសម្ពាធមកលើប្រតិបត្តិការថវិកា និង មកលើការរក្សាទំហំថវិកា។

នៅខែ តុលា ឆ្នាំ ២០១២ ស្ថាប័ននីតិប្រតិបត្តិបានរៀបចំ និងផ្តល់ការឯកភាពលើ សេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ

២០១៣ ដែលសព្វថ្ងៃ កំពុងត្រូវបានបញ្ជូនទៅកាន់ស្ថាប័ននីតិបញ្ញត្តិ (រដ្ឋសភា) ដើម្បីសុំការយល់ព្រមចុងក្រោយ។ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៣ ព្យាយាមបង្កើនចំណូលក្នុងស្រុក ០,៥ ភាគរយនៃ ផសស ជាមួយនឹងកម្រិតចំណាយស្មើនឹងឆ្នាំមុន (ប្រមាណជា ២០ ភាគរយនៃ ផសស)។ ចំណាយមូលធនសម្រាប់គំរោងវិនិយោគអភិវឌ្ឍន៍នៅតែជាអាទិភាពរបស់រដ្ឋាភិបាល ដែលទឹកប្រាក់ចំណាយគ្រោងទុក ស្មើនឹង កម្រិតថវិកាដូចឆ្នាំមុន (ប្រមាណ ជា ៨ ភាគរយ នៃ ផសស)។ ដើម្បីធ្វើហិរញ្ញប្បទានលើមុខចំណាយនេះ ស្ថាប័ននីតិប្រតិបត្តិ (ក្នុងច្បាប់ថវិកាឆ្នាំ ២០១៣) ស្នើសុំខ្ចីប្រាក់រហូតដល់ ៦០០ លាន អេសឌីអ (SDR) សម្រាប់គំរោងវិនិយោគអភិវឌ្ឍន៍ឆ្នាំ ២០១៣។ ជាមួយគ្នានេះ រដ្ឋាភិបាលគ្រោងបង្កើនប្រាក់បៀវត្សមន្ត្រីរាជការ ២០ ភាគរយនៅឆ្នាំ ២០១៣។ នេះគឺជាឆ្នាំទីប្រាំបី តរៀងគ្នានៃការបង្កើនតារាងប្រាក់បៀវត្សចាប់តាំងពីឆ្នាំ ២០០៥ មក។

## ប្រទេសកម្ពុជា៖ សូចនាករណ៍សំខាន់ៗ

| | ឆ្នាំ 2010 | ឆ្នាំ 2011e | ឆ្នាំ 2012f | ឆ្នាំ 2013f | ឆ្នាំ 2014f |
|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | | |
| ផសស ពិត (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 6.0 | 7.1 | 6.6 | 6.7 | 7.0 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 10.7 | 11.8 | 13.0 | 13.4 | 13.8 |
| សន្ទស្សន៍ផលិតកម្មឧស្សាហកម្ម (2000=100) | 263 | 301 | 316 | 341 | 370 |
| (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 13.6 | 14.5 | 5.0 | 8.0 | 8.5 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 3.1 | 4.9 | 4.0 | 5.0 | 5.0 |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរដ្ឋាភិបាល (%នៃ ផសស) | 13.1 | 13.2 | 13.8 | 14.2 | 14.5 |
| ចំណាយរដ្ឋាភិបាល (% នៃ ផសស) | 20.6 | 20.6 | 20.0 | 20.0 | 20.0 |
| តុល្យការរដ្ឋាភិបាល (%នៃ ផសស) | -7.5 | -7.4 | -6.2 | -5.8 | -5.5 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងទូទាត់ និងបំណុលបរទេស** | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -1,582 | -1,490 | -1,680 | -1,807 | -1,941 |
| ទំនិញនាំចេញ (លានដុល្លារអាមេរិក) | 3,884 | 5,220 | 5,768 | 6,460 | 7,235 |
| (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 29.7 | 34.4 | 10.5 | 12.0 | 12.0 |
| ទំនិញនាំចេញសំខាន់ៗ (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) 1/ | 24.4 | 31.7 | 15.0 | 15 | 15 |
| ទំនិញនាំចូល (លានដុល្លារអាមេរិក) | 5,466 | 6,710 | 7,448 | 8,267 | 9,176 |
| (%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 21.7 | 22.7 | 11.0 | 11.0 | 11.0 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) | -1,171 | -1,122 | -1,400 | -1,350 | -1,200 |
| (%នៃ ផសស) | -10.4 | -8.7 | -10.0 | -8.7 | -7.0 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) 2/ | 762 | 1,332 | 1,300 | 1,352 | 1,406 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 3,206 | 3,611 | 3,992 | 4,336 | 4,337 |
| (%នៃ ផសស) | 29 | 28 | 29 | 28 | 25 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | 262 | 264 | 268 | 270 | 275 |
| អនុបាតសេវាបំណុល (%នាំចេញទំនិងនិងសេវាកម្ម) | 1.4 | 1.2 | 1.2 | 1.4 | 1.6 |
| ប្រាក់បំរុងបរទេសដុល (លានដុល្លារអាមេរិក) | 2,653 | 3,032 | 3,456 | 3,871 | 4,335 |
| (ចំនួនខែនាំចូលទំនិញនិងសេវាកម្ម) | 4.5 | 4.5 | 4.5 | 4.5 | 4.5 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 35.3 | 37.7 | 33.0 | 25.0 | 25.0 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 15.0 | 15.0 | 15.0 | 15.0 | 15.0 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លាអាមេរិក ចុងគ្រា) | 4,053 | 4,039 | 4,100 | 4,100 | 4,100 |
| អត្រាប្តូរប្រាក់ប្រសិទ្ធ (2000=100) | 122.5 | 124.8 | 126.2 | .. | .. |
| (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | -0.4 | 1.9 | 1.1 | .. | .. |
| កំណត់ចំណាំ៖ ផសស ជាក់ស្តែង (គិតជាលានដុល្លារអាមេរិក) | 11,242 | 12,828 | 13,944 | 15,473 | 17,053 |

ប្រភព៖ សមត្ថកិច្ចរដ្ឋាភិបាល មូលនិធិរូបិយវត្ថុអន្តរជាតិ

និងការប៉ាន់ស្មានរបស់ធនាគារពិភពលោក

e = ប៉ាន់ស្មាន

f = ការព្យាករណ៍

1/ សម្លៀកបំពាក់

2/ ឆាប់ពីឆ្នាំ ២០១១

គិតទាំងវិនិយោគដោយផ្ទាល់ពីបរទេសដែលទាក់ទងជាមួយតរោងវិស័យ

ថាមពលរដ្ឋនិងឯកជន